ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍សង្ខេប

កិច្ចប្រជុំពេញអង្គសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លើកទី១ ឆ្នាំ២០១៩

ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រកពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឱបត្ថម្ភដោយៈ ថវិកាជាតិ

១. សេចក្តីផ្តើមៈ

នាព្រឹកថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក.ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានដឹកនាំកិច្ចប្រជុំពេញអង្គលើកទី១ ប្រចាំឆ្នាំ២០១៩ នៅសណ្ឋាគារ សង្គហមិត្តគយ ខេត្តកែប ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមួយចំនួនប្រចាំនៅកម្ពុជា។ ជាកិច្ចចាប់ផ្តើម **ឯកឧត្តម អឹង ឆាយ** អភិបាលរងខេត្តកែប តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត បានសំដែងនូវការស្វាគមន៍ដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចំណាយពេលវេលាស្នាក់នៅ និងចូលរួមកិច្ចប្រជុំពេញអង្គក្នុងទឹកដីខេត្តកែបនាពេលនេះ។ ឯកឧត្តម បានបញ្ជាក់ទៀតថាខេត្តកែបមានឆ្នេរសមុទ្រប្រមាណ ២៦.៥គម មានកោះចំនួន១៣ និងមានប្រជាជន ប្រមាណជាង៤០,០០០នាក់ ព្រមទាំងរក្សាបាននូវ សន្តិសុខ សុវត្ថិភាព អភិរក្ស ធ្វើឱ្យមានកំណើនភ្ញៀវ ទេសចរណ៍ជាតិ និងអន្តរជាតិ ដោយសារមានការចូលរួមពីប្រជាពលរដ្ឋក្នុងខេត្តធ្វើការកែលម្អសោភ័ណភាព ទេសភាព បរិស្ថាន បណ្តាលឱ្យទទួលបានពានរង្វាន់រំដួល៣ទងជាប់គ្នា២អាណត្តិ ពានរង្វាន់និរន្តរភាព បរិស្ថានអាស៊ាន និងពាន់រង្វាន់ទីក្រុងស្អាតអាស៊ាន។

ជាកិច្ចបន្ត **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានរំលឹកជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងផ្អែកតាមគម្រោងផែនការសកម្មភាពឆ្នាំ២០១៩ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រារព្ធឡើងជាទៀងទាត់រៀងរាល់៦ខែម្តង។ កិច្ចប្រជុំនាថ្ងៃនេះគឺជាកិច្ចប្រជុំលើកទី១សម្រាប់ឆ្នាំ២០១៩ ដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពនៃការឆ្លើយតបជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងរយៈពេល៦ខែដើមឆ្នាំ២០១៩ រួមជាមួយនិងការប្រើប្រាស់នូវឱកាសដ៏ប្រពៃនេះ សិក្សារៀនសូត្រពីគ្នាទៅវិញទៅមក និងជាពិសេសពិភាក្សារួមគ្នាទៅលើចំណុចខ្វះខាតមួយចំនួន ដែលត្រូវការនូវដំណោះស្រាយតាមរយៈការចូលរួមរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

ដែលមានវត្តមាននាពេលនេះ។ លើសពីនេះទៀតអង្គប្រជុំនឹងមានដាក់ចេញនូវសេចក្តីសម្រេចជាគោលការណ៍មួយចំនួន សម្រាប់ឱ្យក្រុមការងារបច្ចេកទេសយកទៅប្រើប្រាស់ក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពគន្លឹះរយៈពេល៦ខែចុងឆ្នាំ២០១៩ ជាបន្តទៀត។

ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានថ្លែងនូវអំណរគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ដាក់ចេញនូវវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈលិខិតលេខ ២១៣ ស.ជ.ណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវការជំរុញលើកទឹកចិត្តកាន់តែខ្លាំងក្លាបន្ថែមទៀត ដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការបំពេញការងារឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ លើសពីនេះទៀតឯកឧត្តមបានថ្លែងអំណរគុណដល់សមាជិក សមាជិកា ដែលបានចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ និងបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងក្នុងការអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ ស.ជ.ណ.សស រហូតមានការវិវឌ្ឍខ្លះៗក្នុងរយៈពេល ៦ខែដើមឆ្នាំ២០១៩នេះ និងសូមប្រកាសបើកកម្មវិធីសម្រាប់កិច្ចប្រជុំពេញអង្គលើកទី១ប្រចាំឆ្នាំ២០១៩ តាមរបៀបវារៈដែលបានគ្រោងទុក។

២. សមាជិកចូលរួម៖ (មានចំនួន១៦៨នាក់ ស្ត្រីចំនួន២៥នាក់)

- ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន ចំនួន៣០
- ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ចំនួន២៥
- ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ចំនួន២៥
- តំណាងអង្គការសង្គមស៊ីវិលចំនួន៩

៣. គោលបំណង ៖

ឯកឧត្តមវេជ្ជ. តែង គង្គី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីគោលបំណងនៃកិច្ចប្រជុំដូចខាងក្រោម:

- ផ្តល់ជូនសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- ផ្តល់ជូនសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។
- ស្នើសុំការអនុម័តនូវសេចក្តីសម្រេចចិត្ត របស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ប្រចាំឆ្នាំ២០១៩។

កិច្ចប្រជុំមានបទបង្ហាញតាមរបៀបវារៈដូចខាងក្រោម:

- ✓ សុន្ទរកថាបើកកិច្ចប្រជុំពេញអង្គដោយ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**។
- ✓ បច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា
- ✓ វឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។
- ✓ របាយការណ៍របស់ក្រសួងពាក់ព័ន្ធស្តីពីការអនុវត្ត ស.ជ.ណ ២១៣
- ✓ ការអនុម័តសេចក្តីសម្រេចចិត្តរបស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩។
- ✓ សុន្ទរកថាបិទកិច្ចប្រជុំពេញអង្គដោយ **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**។

៤. សុន្ទរកថាបើកកិច្ចប្រជុំ ដោយ ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានប្រសាសន៍បញ្ជាក់ថា សមិទ្ធផលដែលគួរជាទីមោទនៈ ដែលសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រេចបាននៅក្នុងឆ្នាំ២០១៨ គឺទទួលបាននូវការគាំទ្រជានយោបាយដ៏មោះមុតពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមប្រធានអង្គប្រជុំ** បានទាញការចាប់អារម្មណ៍ថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចជាគោលការណ៍ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការលុបបំបាត់ជំងឺអេដស៍ តាមរយៈការកំណត់យ៉ាងច្បាស់លាស់នូវគោលដៅសូន្យបីគឺ "គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ និងគ្មានការស្លាប់ដោយសារជំងឺអេដស៍" ព្រមទាំងឆ្ពោះទៅសម្រេចឱ្យបានគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ (៩៥% នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេ ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យ ហើយបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩៥%នៃអ្នកទាំងអស់ ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន) នៅឆ្នាំ២០២៥។

ជារួមប្រទេសកម្ពុជាកំពុងតែឈរនៅលើផ្លូវត្រូវ យើងកំពុងតែធ្វើត្រូវក្នុងក្តីសង្ឃឹមពិតប្រាកដឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍តាមការកំណត់ ដោយសារតែប្រទេសកម្ពុជាមានកត្តាចាំបាច់ដ៏មានប្រសិទ្ធភាពខ្ពស់រួចទៅហើយ គឺការប្តេជ្ញាចិត្តគាំទ្រជានយោបាយ ប្រកបដោយទស្សនវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រួមជាមួយនឹងកត្តាគ្រប់គ្រាន់មួយចំនួនគឺ៖ មានចីរភាពនៃការចូលរួមឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ និងការចូលរួមជាដៃគូនៃប្រទេសជាមិត្ត និងស្ថាប័នអន្តរជាតិ សង្គមស៊ីវិលវិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។ល។ មានប្រព័ន្ធតាមដានការពាលដាលមេរោគអេដស៍ និងជំងឺអេដស៍បានជាប្រចាំ មានស្ថាប័នដឹកនាំ គ្រប់គ្រង និងសម្របសម្រួលតែមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធតាមដាននិងវាយតម្លៃជាតិតែមួយប្រកបដោយប្រសិទ្ធភាពខ្ពស់។

ឯកឧត្តមប្រធានអង្គប្រជុំ បានបន្ថែមទៀតថា ដូចគ្នាជាមួយប្រទេសនានាក្នុងសកលលោក និងក្នុងតំបន់ផងដែរ បញ្ហាដែលកម្ពុជាកំពុងបន្តប្រឈមមកដល់ពេលនេះ និងទៅខាងមុខ គឺជាបញ្ហាធនធានមនុស្សដែលទាមទារនូវការកសាងសមត្ថភាពពេញលេញ ពីយុទ្ធសាស្ត្រ វិទ្យាសាស្ត្រថ្មីៗ ធនធានសម្ភារបរិក្ខារក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងធនធានថវិកា ដែលជាបញ្ហាប្រឈមខ្ពស់ជាងគេក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ។ ដូច្នេះទាមទារនូវការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រើប្រាស់គ្រប់លទ្ធភាពទាំងអស់ ក្នុងការចលនាធនធានពីគ្រប់ប្រភពទាំងអស់រួមជាមួយនឹងការធានាដល់ការចំណាយធនធានដែលមានស្រាប់ ប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយចៀសវាងឱ្យបាននូវការចំណាយច្រើនទទួលបានផលតិចឬការចំណាយជាន់គ្នាជាដើម។ល។

ឯកឧត្តមប្រធានអង្គប្រជុំ បានជូនពរឱ្យកិច្ចប្រជុំនេះ ដំណើរការប្រកបដោយផ្លែផ្កាក្រោមការពិភាក្សាយ៉ាងសកម្ម ដែលនឹងរួមចំណែកក្នុងការបង្កើតគំនិតគន្លឹះសំខាន់ៗបន្ថែមទៀត សម្រាប់ផ្តល់ជូនអ្នកបច្ចេកទេសអាចយកទៅប្រើប្រាស់ក្នុងការបន្តការរៀបចំអនុវត្ត និងសូមប្រសិទ្ធពរជូនឯកឧត្តមលោកជំទាវ លោក លោកស្រីទទួលបាននូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

៥. បទបង្ហាញ និងដំណើរការកិច្ចប្រជុំ៖

ប្រធានបទទី១: បទបង្ហាញពីបច្ចុប្បន្នភាពនៃស្ថានភាពរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា បង្ហាញដោយ **ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

- ✓ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំបន្ទាន់មួយដើម្បីលើកជាវិធានរួមដើម្បីអនុវត្តសេចក្តីជូនដំណឹងលេខ២១៣ ស.ជ.ណ.សស ដោយបានរៀបចំផែនការបច្ចេកទេស និងរៀបចំការតាមដានការអនុវត្តនេះផងដែរ។
- ✓ នៅខែកុម្ភៈ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានដឹកនាំគណៈប្រតិភូ បំពេញបេសកកម្មចូលរួមសន្និសីទពានរង្វាន់ព្រះអង្គម្ចាស់ម៉ាហ៊ីដុល ឆ្នាំ២០១៩ លើប្រធានបទ «**នយោបាយសេដ្ឋកិច្ចនៃជំងឺមិនឆ្លង**» នៅទីក្រុងបាងកកប្រទេសថៃដើម្បីបង្ហាញពីមេរៀនជាបទពិសោធន៍ ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ដែលអាចប្រើប្រាស់ជាគំរូមួយក្នុងការប្រយុទ្ធទប់ស្កាត់ជំងឺមិនឆ្លង(NCD)។
- ✓ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំក្រុមការងាររួមគ្នារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍលើការងារប្រយុទ្ធនឹងជំងឺអេដស៍(GDJ-TWG on HIV/AIDS) លើកទី១ ឆ្នាំ២០១៩ ដោយសម្រេចបាននូវ៖
    - ធ្វើបច្ចុប្បន្នភាពនៃការចាប់ផ្តើមជុំនៃជំនួយមូលនិធិសកល ឆ្នាំ២០១៨-២០២០
    - ពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ដើម្បីធ្វើការវិភាគអំពីស្ថានភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ និងត្រៀមរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៥។
    - ត្រៀមផ្សព្វផ្សាយរបាយការណ៍វាយតម្លៃលើការត្រៀមខ្លួន ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងដំណាក់កាលអន្តរកាល(Transition Period) ។
- ✓ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** និងថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ បានជួបទទួលគណៈប្រតិភូសមាគម Asia Horizon 2020 ពីប្រទេសបារាំង ដឹកនាំ ដោយលោកវេជ្ជបណ្ឌិត Robert Andrei ពិភាក្សាការងារប្រយុទ្ធនឹងការឆ្លងរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជាតាមរយៈគម្រោងបណ្តុះបណ្តាលអប់រំជាពិសេសស្ត្រីក្នុងការបង្ការការចម្លងមេរោគអេដស៍ ព្រោះស្ត្រីកម្ពុជាជានិច្ចជាកាលនៅតែជាជនរងគ្រោះ និងប្រឈមការឆ្លងមេរោគអេដស៍។
- ✓ នៅខែកុម្ភៈ ឆ្នាំ២០១៩ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានទៅធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលការពារជំងឺអេដស៍ នៅទីក្រុងញូវដេលី។ ក្នុងនោះបានចូលរួមពិធីប្រកាសអំពីសមិទ្ធផលផ្នែកសុខាភិបាលរបស់ប្រទេសឥណ្ឌា ដោយមានការចូលរួមពីរដ្ឋមន្ត្រីសុខាភិបាលប្រទេសឥណ្ឌា អ៊ូហ្គង់ដា រ៉ាន់ដា លីបេរីយ៉ា ប្រធានប្រតិភូសហគមន៍អឺរ៉ុប អគ្គនាយករងអង្គការសុខភាពពិភពលោក ឯកអគ្គរដ្ឋទូតបារាំង ប្រធានក្រុមប្រឹក្សាកិបាលមូលនិធិសកល និងថ្នាក់ដឹកនាំក្រសួងសុខាភិបាលឥណ្ឌា។

- ✓ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានចូលរួមក្នុងកិច្ចប្រជុំត្រៀមសម្រាប់កៀរគរថវិកាជំនួយផ្តល់ដល់មូលនិធិសកល ឆ្នាំ២០២០-២០២២ (Global Fund's budget 2020-2022)។
- ✓ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** និងជាសមាជិកក្រុមប្រឹក្សាកិបាលមូលនិធិសកល បានដឹកនាំគណៈប្រតិភូមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកិបាលមូលនិធិសកល ធ្វើឡើងពីរដងក្នុងមួយឆ្នាំដើម្បីពិភាក្សាអំពីកិច្ចការដែលបានធ្វើកន្លងមក និងអនុម័តសេចក្តីសម្រេចនានាក្នុងការអនុវត្តការងារបន្តនាឆ្នាំខាងមុខ។
- ✓ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានជួបពិភាក្សាជាមួយលោក Michel Sidibe អគ្គនាយកអង្គការ UNAIDS នៅប្រទេសស្វីស ក្នុងខែមេសា ធ្វើឡើងក្នុងពេលដែលអង្គការ UNAIDS រៀបចំកិច្ចប្រជុំពិគ្រោះយោបល់សកលស្តីពី "ការគូសវាសផ្លូវដើរទៅកាន់លទ្ធផលនៃការឆ្លើយតបនឹងជំងឺអេដស៍ ប្រកបដោយចីរភាពក្នុងយុគសម័យគោលដៅអភិវឌ្ឍប្រកបដោយចីរភាព" ក្នុងឱកាសនោះអង្គការ UNAIDS បានប្រគល់នូវវិញ្ញាបនបត្រទទួលស្គាល់នូវការប្តេជ្ញាចិត្តជានយោបាយ និងមគ្គទ្ទេសក៍ភាព ដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យសម្រេចនូវគោលដៅ ៩០-៩០-៩០ ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។
- ✓ នៅខែកុម្ភៈ ឆ្នាំ២០១៩ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានចូលរួមក្នុងកិច្ចប្រជុំត្រៀមសម្រាប់កៀរគរកថវិកាជំនួយ ផ្តល់ដល់មូលនិធិសកលឆ្នាំ២០២០-២០២២ ដោយមានបទបង្ហាញពីអ្នកជំនាញខាងផ្នែកសុខាភិបាល ព្រមទាំងប្រធាន គណៈប្រតិភូប្រទេសផ្តល់ជំនួយដូចជា ប្រទេសស៊ុយអែត អាល្លឺម៉ង់ បារាំង ជប៉ុន ន័រវែស។ល។ ប្រទេសនីមួយៗបានសម្តែងសុទិដ្ឋិនិយម អំពីជំនួយទឹកប្រាក់ដែលពួកគេនឹងប្រកាសនៅប្រទេសបារាំង នាខែតុលា ឆ្នាំ២០១៩ ខាងមុខ។ គោលដៅនៃការកៀរគរកជំនួយបានកំណត់ក្នុងរង្វង់**១៤ពាន់លានដុល្លារអាមេរិក**។ ប្រទេសលុចសំបួ បានប្រកាសមុនគេថានឹងផ្តល់ថវិកាចំនួន **៩លានអឺរ៉ូ** សម្រាប់កម្មវិធីមូលនិធិសកលឆ្នាំ២០២០-២០២២។
- ✓ នៅខែឧសភា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាស្តីពីការចូលរួមចំណែកនៃវិស័យឯកជនក្នុងបញ្ហាសុខភាព ការឆ្លើយតបមរោគអេដស៍ និងជំងឺអេដស៍។ ក្នុងឱកាសនោះ **ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** បានគូសបញ្ជាក់ថា វិស័យឯកជនបានចូលរួមយ៉ាងសកម្មក្នុងការចូលរួមកំណើនសេដ្ឋកិច្ច និងវិស័យមនុស្សធម៌ ហើយជំរុញវិស័យឯកជនចូលរួមសកម្មបន្ថែមទៀតក្នុងការសម្រេចនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ចប់បញ្ហាអេដស៍នៅកម្ពុជាជាពិសេសក្នុងដំណាក់កាលថយចុះថវិកាជំនួយពីខាងក្រៅ។

បន្ទាប់មកទៀត **ឯកឧត្តមវេជ្ជ. ហោ ចុនឡេច** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានបង្ហាញពីសកម្មភាពរបស់ក្រសួង ស្ថាប័នដែលជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(ឯកសារដូចមានក្នុងស្លាយ)។

ចំពោះវឌ្ឍនភាព និងសមិទ្ធផលនៃយុទ្ធសាស្ត្រថៃទាំ និងព្យាបាល យើងពុំមានព័ត៌មានឆ្នាំ២០១៩ ដូចនេះយើងប្រើប្រាស់ព័ត៌មានដែលមានក្នុងឆ្នាំ២០១៨។ ចំនួនទីកន្លែងផ្តល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅត្រីមាសទី៤ ឆ្នាំ២០១៨ មានចំនួន៦៦កន្លែង ចំណែកចំនួនអ្នកផ្ទុកមេរោគអេដស៍ជាមនុស្សពេញវ័យដែលបានទទួលសេវាព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ពីឆ្នាំ២០១៤ ដល់ត្រីមាសទី៤ឆ្នាំ២០១៨ មានចំនួន៥៦,៧២៦នាក់ ក្នុងនោះមានកុមារចំនួន៣,១១១នាក់។ ទន្ទឹមនោះស្ត្រីមានផ្ទៃពោះដែលបានទទួលការធ្វើតេស្តឈាមរកមេរោគអេដស៍រហូតដល់៩៧% ព្រមទាំងអ្នកដែលរកឃើញថាមានផ្ទុកមេរោគអេដស៍ ហើយទទួលបានឱសថប្រឆាំងមេរោគអេដស៍រហូតដល់៩៣.៦០%។

ចំពោះវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ ក្រសួងផែនការបានសម្របសម្រួលដាក់បញ្ចូលគ្រួសាររងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជនងាយរងគ្រោះដើម្បីទទួលប័ណ្ណសមធម៌តាមនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រជនបទ និងទីប្រជុំជនក្នុងខេត្តចំនួន៨ រួមមាន ខេត្តតាកែវ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តព្រះវិហារ និងខេត្តរតនគីរី និង១៦ខេត្តផ្សេងទៀត នឹងផ្តល់ប័ណ្ណសមធម៌តាមនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ។ ម្យ៉ាងទៀតដើម្បីជួយសម្រួលដល់ការរក្សាភាពសម្ងាត់ក្រសួងផែនការយល់ព្រមផ្តល់ប័ណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ជាលក្ខណៈបុគ្គលនៅនឹងកន្លែងផ្តល់ឱសថប្រឆាំងមេរោគអេដស៍ តាមសំណូមពររបស់លោកមេឃុំ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង UNAIDS បានធ្វើបច្ចុប្បន្នភាព AIDS Epidemic Model និង Spectrum File ដើម្បីប៉ាន់ស្មាន និងទស្សន៍ទាយថ្មីពីចំនួន និងអត្រាផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ (HIV estimates and Projections)បានបញ្ចប់ការប៉ាន់ប្រមាណនិងទស្សន៍ទាយថ្មីពីចំនួន និងអត្រាផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាលទ្ធផលបឋមបានបង្ហាញថា៖

- ចំនួនអ្នកផ្ទុកមេរោគអេដស៍មានការកើនឡើង

- មានការកើនឡើងករណីឆ្លងមេរោគអេដស៍ថ្មី ជាពិសេសចំនួន និងអត្រាប្រ៉ាឡង់មានការកើនឡើងក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងករណីស្លាប់ទាក់ទងនឹងជំងឺអេដស៍មានការថយចុះ។

បានបញ្ចប់របាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាឆ្នាំ២០១៩ (GARPR 2019) ផ្ញើជូនទៅអង្គការសហប្រជាជាតិ និងបានរៀបចំរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទាក់ទងនឹងសូចនាករអភិវឌ្ឍប្រកបដោយចីរភាព (Cambodian Sustainable Development Goal) ផ្ញើជូនក្រសួងផែនការ។

ប្រធានបទទី២: បទបង្ហាញពីវឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ បង្ហាញដោយ **ឯកឧត្តមវេជ្ជ. ង៉ា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

ចំពោះយុទ្ធសាស្ត្រថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ដោយឱសថប្រឆាំងនឹងមេរោគអេដស៍ បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព ដែលគោលដៅ ៩៥% នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេគឺសម្រេចបាន៨១% និង៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ ដែលបានធ្វើរោគវិនិច្ឆ័យហើយបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំគឺ សម្រេចបាន៩៩% ចំណែក៩៥%នៃអ្នកទាំងអស់ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួនគឺសម្រេចបាន៧៩% ដែលអាចឈានទៅសម្រេចបាននូវគោលដៅ៩៥-៩៥-៩៥ក្នុងឆ្នាំ២០២៥ ខាងមុខនេះ។

ឯកឧត្តមបានបញ្ជាក់ថា ដើម្បីឱ្យការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ មានប្រសិទ្ធភាពកម្ពុជាត្រូវការវិនិយោគ២០លានដុល្លារក្នុង១ឆ្នាំ។ សម្រាប់ការឆ្លើយតបនៅមូលដ្ឋាន គឺជាតម្រូវការចាំបាច់សម្រាប់ឱ្យកម្មវិធីបង្ការពេញលេញ ការស្វែងរកអ្នកផ្ទុក និងកាត់បន្ថយផលប៉ះពាល់អតិបរមា។ ក្នុងនោះដែរឯកឧត្តម បានសំដែងការអបអរសាទរចំពោះសមិទ្ធផល នៃរបាយការណ៍ការអនុវត្តកម្មវិធីឆ្នាំ២០១៨ថា សូចនាករគ្របដណ្តប់ និងលទ្ធផលទាំង១៦ដែលបានរាយការណ៍ នៅក្នុងឆ្នាំ២០១៨ មានដូចខាងក្រោម៖

- ៦ សូចនាករដែលសម្រេចបានតាមគោលដៅ ជាង 100% (A1)

- ៣ សូចនាករដែលសម្រេចបានរវាង 90% - 100% ធៀបនឹងគោលដៅ (A2)
- ៥ សូចនាករដែលសម្រេចបានរវាង 60% -89% ធៀបនឹងគោលដៅ (B1)
- ២ សូចនាករដែលសម្រេចបានតិចជាង 60% ធៀបនឹងគោលដៅ (B2)

➢ ការចូលរួមមតិយោបល់

ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តស្វាយរៀង ស្នើសុំឱ្យមានការពន្យល់ពីសូន្យទី២ដែលមានន័យថាកុំឱ្យមានការស្លាប់ដោយសារជំងឺអេដស៍ លោកបានបញ្ជាក់ថាហាក់មានន័យថាធ្វើយ៉ាងណាកុំឱ្យអ្នកផ្ទុកមេរោគអេដស៍ស្លាប់ ជាករណីដែលមិនអាចធ្វើបាន។ ក្រោយពីពិភាក្សាបានសម្រេចកែសម្រួលទៅជា «មិនឱ្យមានស្លាប់ដោយសារជំងឺអេដស៍ដោយមិនបានទទួលការព្យាបាល»។

ប្រធានបទទី៣: បទបង្ហាញ និងការអនុម័តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដសលើកទី១ ឆ្នាំ២០១៩ បង្ហាញដូនដោយឯកឧត្តម **ឈឹម ឃិនជារ៉ែត** នាយកខុទ្ទកាល័យ និងជាអគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអានសេចក្តីព្រាងនៃសេចក្តីសម្រេចចិត្តរបស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៩ ទាំងស្រុង។ ក្រោយពីបានពិនិត្យ និងពិភាក្សា មានការស្នើសុំឱ្យមានការកែសម្រួលដូចខាងក្រោម៖

- ✓ គោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ ទៅជាគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ តាមកាលកំណត់(២០២៥-២០៣០)។
- ✓ បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ ឯកភាពកែសម្រួលឃ្លា(បានប្តេជ្ញាបន្តនូវឆន្ទៈរួមគ្នាក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានជោគជ័យ)ទៅជា បានប្តេជ្ញាបន្តនូវឆន្ទៈរួមគ្នាដោយទទួលខុសត្រូវខ្ពស់ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ឱ្យបានជោគជ័យ។
- ✓ **ឯកឧត្តម រៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ពន្យល់ខ្លឹមសារចំណុចទី២ នៃសេចក្តីសម្រេចចិត្តថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តពិភាក្សាគន្លឹះដើម្បីជួយ ជាពិសេស ចលនាធនធាន ដើម្បីជួយការងារអេដស៍ ដោយលើកឧទាហរណ៍ អង្គការPSI រកស៊ីលក់ស្រោមអនាម័យ តែត្រូវចំណាយលុយជួយធ្វើ Spot ផ្សព្វផ្សាយស្រោមអនាម័យ។ ចំពោះចំណុចទី២សម្រេចកែសម្រួលពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បន្តទាក់ទងជាមួយនឹងវិស័យឯកជន ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការចូលរួមរបស់វិស័យឯកជនក្នុងការ

ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ទៅជាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បន្ត ទាក់ទងជាមួយវិស័យឯកជន និងសប្បុរសជនព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីពង្រឹងការចូលរួមរបស់វិស័យឯកជន និងសប្បុរសជនក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ក្រោយកិច្ចពិភាក្សាយ៉ាងសកម្ម និងមានប្រសិទ្ធភាពពីសំណាក់សមាជិក សមាជិកានៃអង្គប្រជុំ បានឯកភាពលើសេចក្តីព្រាងនៃសេចក្តីសម្រេចចិត្ត របស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៩ដូចខាងក្រោម៖

សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១

ឆ្នាំ២០១៩ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩÷

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩ បានដំណើរការរយៈពេលមួយព្រឹកពេញ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ នៅសណ្ឋាគារសង្គហមិត្តគយ ខេត្តកែប ដោយមានការចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមការងាររេខាធិការដ្ឋាន ក្រសួង ស្ថាប័ន ចំនួន៣០ រាជធានី ខេត្តទាំង២៥ អង្គការ និងសង្គមស៊ីវិល ចំនួន៩ សរុបចំនួន១៦៨រូប។

អង្គប្រជុំទាំងមូលបានធ្វើការគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដាក់ចេញនូវវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈសេចក្តីជូនដំណឹងលេខ២១៣សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវការជំរុញលើកទឹកចិត្តកាន់តែខ្លាំងក្លាបន្ថែមទៀតដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធទាំងអស់ក្នុងការបំពេញការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានថ្លែងអំណរគុណ និងកោតសរសើរផេងដៃចំពោះសមាជិក សមាជិកា នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨ ដែលបានលើកគំនិតប្រកបដោយការទទួលខុសត្រូវខ្ពស់

ក្នុងការរៀបចំឱ្យមានសេចក្តីសម្រេចចិត្តដ៏ល្អមួយ នាំដល់ការស្នើសុំរាជរដ្ឋាភិបាលសម្រេចចេញនូវវិធានការខាងលើ។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់បានប្តេជ្ញាបន្តនូវឆន្ទៈរួមគ្នា ដោយទទួលខុសត្រូវខ្ពស់ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ឱ្យបានជោគជ័យ តាមរយៈការធ្វើឱ្យសម្រេចនូវគោលនយោបាយសូន្យបី"សូន្យនៃការឆ្លងមេរោគអេដស៍ថ្មី សូន្យនៃការមាក់ងាយ និងរើសអើង និងសូន្យនៃការស្លាប់ដោយសារជំងឺអេដស៍ដោយមិនបានទទួលការព្យាបាល" និងគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ តាមកាលកំណត់នៅឆ្នាំ២០២៥-២០៣០ (៩៥%នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេ ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យហើយបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩៥%នៃអ្នកទាំងអស់ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍ នៅក្នុងខ្លួនដែលលែងជាគ្រោះគំរាមកំហែងដល់អ្នកផ្ទុកមេរោគអេដស៍)។

នៅក្នុងគោលបំណងសម្រេចនូវឆន្ទៈខាងលើ កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ ៖

១. ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងវិធានការទាំង៦ដែលបានកំណត់ក្នុងកិច្ចប្រជុំអន្តរក្រសួងកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា បន្តធ្វើការតាមដានត្រួតពិនិត្យ វាយតម្លៃវឌ្ឍនភាពនៃវិធានការដែលបានកំណត់ ដើម្បីឱ្យតំណាងក្រសួងស្ថាប័នទាំងនោះ អាចនាំយករបាយការណ៍មកជម្រាបជូនកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៩ខាងមុខ។

២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តទាក់ទងជាមួយវិស័យឯកជន និងសប្បុរសជននានា ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការចូលរួមរបស់វិស័យឯកជន និងសប្បុរសជនក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៦. សុន្ទរកថាបិទអង្គប្រជុំ៖

ឯកឧត្តម អៀង មុលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានប្រសាសន៍ថា ឆ្លងកាត់ការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក ដែលសម័យប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញរួមជាមួយនឹងការពិភាក្សា និងផ្តល់ជាយោបល់យ៉ាងផុសផុលដែលនាំឱ្យ

សម័យប្រជុំពេញអង្គរបស់ទាំងមូលទទួលបាននូវលទ្ធផលគួរជាទីមោទនៈ សមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះដែលបានសង្ខេបជូនដូចតទៅ ៖

ទី១ : ការអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍៦ខែដើមឆ្នាំ២០១៩។

ទី២ : ការអនុម័តជាគោលការណ៍ផែនការជាតិឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់រយៈពេល ៦ខែចុងឆ្នាំ២០១៩។

ទី៣ : សមាជិក សមាជិកានៃកិច្ចប្រជុំពេញអង្គបានប្តេជ្ញាចិត្តក្នុងការបន្តរៀបចំផែនការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣សជណ.សស" ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទី៤ : កិច្ចប្រជុំពេញអង្គបានឯកភាពអនុម័ត ចេញនូវសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៩ សម្រាប់បន្តអនុវត្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។

ទោះបីជាពេលវេលារបស់យើងមានពេលតែមួយព្រឹកក៏ពិតមែន តែដោយសារតែមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុត ជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ឯកឧត្តមប្រធានអង្គប្រជុំ បានអនុញ្ញាតឆ្លៀតក្នុងឱកាសមុនបិទសម័យប្រជុំពេញអង្គដោយផ្តល់ជូននូវការចាប់អារម្មណ៍បូកសរុបលទ្ធផលជារួម ដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព៦ខែដើមឆ្នាំ២០១៩ ទៅតាមក្រសួង ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រាន់តែលទ្ធផលដែលយើងទទួលគឺអាចខុសៗគ្នា ទៅតាមស្ថានភាពជាក់ស្តែងរបស់ស្ថាប័ននីមួយៗ។

២) ប្រទេសកម្ពុជារបស់យើងនៅតែមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការត្រួតពិនិត្យការរាលដាលមេរោគអេដស៍ឱ្យបន្តធ្លាក់ចុះជាបន្តបន្ទាប់ទៅទៀតមានលទ្ធភាពផ្តល់ការថែទាំ និង

ព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដល់អ្នកដែលត្រូវការបានលើសពី៨០% និងពុំមានរបាយការណ៍ស្តីពីការរើសអើងអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ទេ។

៣) អបអរសាទរចំពោះក្រសួងផែនការ ដែលបានសម្របសម្រួលបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងក្រុមប្រជាជនដែលបានទទួលប័ណ្ណក្រីក្រជាបន្តបន្ទាប់។

៤) លើកទឹកចិត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានជួយបង្កើន និងសម្របសម្រួលដល់ការប្រើប្រាស់ថវិកាជាតិ ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។

៥) លើកទឹកចិត្តក្រសួង រដ្ឋលេខាធិការដ្ឋាន ខេត្តរាជធានីដែលមិនទាន់បានធ្វើរបាយការណ៍មកកាន់លេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យធ្វើរបាយការណ៍ទាន់ពេលវេលា។

៦) កង្វះខាតថវិកានៅតែជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញទៅតាមការគ្រោងទុក ឬក៏លទ្ធភាពក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅកាន់ភូមិសាស្ត្រថ្មី ក្រុមគោលដៅថ្មី។

ជាមួយគ្នានេះផងដែរ **ឯកឧត្តមប្រធានអង្គប្រជុំ** បានផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ទៅរៀបចំបញ្ចប់របាយការណ៍៦ខែដើមឆ្នាំ២០១៩ និងកែលម្អនូវគម្រោងផែនការសកម្មភាព៦ខែចុងឆ្នាំ២០១៩។

២) បន្តចូលរួមជា "**ចលនាជាតិមួយ**" ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

៣) លើកទឹកចិត្តជូនសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យខិតខំបង្កើនសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចឱ្យបាននូវគោលនយោបាយសូន្យបី និងដោយឡែកសម្រាប់ក្រសួងសុខាភិបាលក្នុងការអនុវត្តគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ តាមកាលកំណត់នៅឆ្នាំ២០២៥-២០៣០។

៤) បន្តអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៥) សូមជំរុញលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកសំណើថវិកាឆ្នាំ២០២០ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័ន។

៦) សូមគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ជំរុញការផ្តល់របាយការណ៍តាមរយៈការពង្រឹងការអនុវត្តគោលការណ៍បីមួយៈ ស្ថាប័នដឹកនាំសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងប្រព័ន្ធតាមដានត្រួតពិនិត្យតែមួយ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងធ្វើការវាយតម្លៃ និងចេញប័ណ្ណសរសើរនៅក្នុងកិច្ចប្រជុំពេញអង្គ លើកទី២ នៅចុងឆ្នាំ២០១៩។

៧) អំពាវនាវដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបន្តធ្វើវិនិយោគថវិកាជាតិបន្ថែមទៀត ដើម្បីពន្លឿនការសម្រេចបាននូវគោលដៅទៅតាមការគ្រោងទុក។

៨) អំពាវនាវដល់ដៃគូអភិវឌ្ឍ និងវិស័យឯកជនក្នុងការបន្តការផ្តល់ជំនួយទាំងបច្ចេកទេស សម្ភារ និងថវិកាដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាតទៅទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ជាស្ថាពរ។

ជាថ្មីម្តងទៀត **ឯកឧត្តមប្រធានអង្គប្រជុំ** បានថ្លែងអំណរគុណជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងសម័យប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ តាមរយៈការចូលរួមយ៉ាងសកម្មផ្តល់នូវគំនិតល្អៗ និងមានតម្លៃ សម្រាប់យកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានសម្តែងនូវការកោតសរសើរផែងដៃជូនចំពោះអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំសម័យប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបានជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាចុងក្រោយ **ឯកឧត្តមប្រធានអង្គប្រជុំ** បានប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព និងប្រកាសបិទ

"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩" ជាផ្លូវការ ចាប់ពីពេលនេះតទៅ។

កិច្ចប្រជុំបានបញ្ចប់ទៅដោយជោគជ័យ និងទទួលបានលទ្ធផលជាផ្លែផ្កានៅវេលាម៉ោង ១២:៤០នាទី ក្នុងថ្ងៃដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

ថ្ងៃអង្គារ ៩កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩

បានឃើញ និងឯកភាព	**បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់**	បានពិនិត្យត្រឹមត្រូវ
ប្រធានអង្គប្រជុំ	**អគ្គលេខាធិការ**	ប្រធាននាយកដ្ឋានទាក់ទង
		និងចលនាប្រកពធនធាន
	វេជ្ជ.តែង គន្ធី	
		ទេជ្ជ. ឈា សិទ្ធិ